មាតិកា

ប្រជារាស្ត្រខ្មែរ និង នយោបាយ ..... 1
សេចក្តីផ្តើម ..... 1
ប្រជាពលរដ្ឋ ..... 2
ប្រជាជន ..... 3
ប្រជារាស្ត្រ ..... 4
វប្បធម៌ នយោបាយ ..... 6
វប្បធម៌ នយោបាយ នៃ ប្រជារាស្ត្រខ្មែរ ..... 9

# ប្រជារាស្ត្រខ្មែរ និង នយោបាយ

## សេចក្តីផ្តើម

មាន ពាក្យ បី យ៉ាង : ប្រជារាស្ត្រ, ប្រជាពលរដ្ឋ និង ប្រជាជន ដែល ខ្មែរ យក មក ប្រើ សំរាប់ សំគាល់ សហពន្ធ ជាតិ ខ្មែរ។ សួរ ថា តើ ការ ៩ ឈ្មោះ បី យ៉ាង នេះ មាន ន័យ ខុសគ្នា បែបណា ?

# ប្រជារាស្ត្រខ្មែរ និង នយោបាយ

យើង សាងល្បង យក ពាក្យ ទាំង បី នេះ មក ធ្វើ វិភាគ ដើម្បី ស្វែង រក ធាតុ ពិត របស់ ពាក្យ នីមួយៗ :

ប្រជារាស្ត្រ ជា ពាក្យ ឲ ទម្ងន់ ទៅ លើ អត្ថរស ពីរ យ៉ាង គឺ, អត្ថរស នៃ វណ្ណៈ ក្នុង សង្គម និង អត្ថរស នៃ ប្រវត្តិសាស្ត្រ។ បើ យើង ប្រើ ពាក្រ រាស្ត្រ គឺ ជា ពាក្យ គូ នឹង ពាក្យ ក្សត្រ ឬ ស្តេច, ដូច្នេះ វា បង្ហាញ នូវ រូបភាព ជា វណ្ណៈ នៃ មនុស្ស ក្នុង សង្គម នោះ ឯង។ តែ ពាក្យ នេះ ក៏ មាន អត្ថរស ជា ប្រវត្តិសាស្ត្រ នោះ ដែរ ព្រោះ ថា ពាក្យ នេះ ខ្មែរ យើង ធ្លាប់ តែ ប្រើ អស់ ច្រើន សតវត្ស រួចមក នៅ ក្នុង របប រាជានិយម។

## ប្រជាពលរដ្ឋ

ប្រជាពលរដ្ឋ ជា ពាក្យ ឲ ទម្ងន់ ទៅ លើ អត្ថរស ពីរ យ៉ាង ដែរ គឺ, អត្ថរស នៃ វណ្ណៈ តែ ចង់ ចង្អុល ចំ វណ្ណៈ ទី ៤ នៃ ព្រហ្មញ្ញសាសនា ដែល អ្នក ដឹកនាំ ខ្មែរ ក្នុង របប សក្តិភូមិ ចាត់ ទុក ជា ទាសៈ ទាសី ឬ មនុស្ស ខ្ញុំគេ ជា ពល កម្លាំង សំរាប់ គេ ប្រើ ដូច បសុសត្វ តែ ពាក្យ នេះ ក៏ មាន អត្ថរស ជា កម្លាំង ទ័ព នោះ ដែរ ព្រោះ និយាយ ថា ពលរដ្ឋ គឺ និយាយ អំពី កម្លាំង របស់ជាតិ សំរាប់ អ្នក ដឹកនាំ កេណ្ឌ ធ្វើ ទាហាន នៅ ពេល ស្រុក មាន សង្គ្រាម, ជា សង្គ្រាម ការពារ ជាតិ ក្តី, ការពារ អំណាច ក្តី។

# ប្រជារាស្ត្រខ្មែរ និង នយោបាយ

## ប្រជាជន

ប្រជាជន ជា ពាក្យ ៩ ទម្ងន់ ទៅ លើ អត្ថរស ពីរ យ៉ាង ដូច គ្នា គឺ អត្ថរស នៃ នយោបាយ គឺ ចង់ បង្ហាញ ថា ជន ម្នាក់ៗ ជា បុគ្គល មាន សេរីភាព ជា ម្ចាស់ លើ ខ្លួន ឯង ឥត នៅ ក្រោម វណ្ណៈ ណា មួយ នោះ ឡើយ, ពាក្យ នេះ ជា ពាក្យ សម័យ ដែល អ្នក បដិវត្តន៍ យក មក ប្រើ ដើម្បី ដាស់ ស្មារតី នៃ វណ្ណៈ រាស្ត្រ ៩ ស្គាល់ នូវ សិទ្ធិ ខ្លួន ជា ជន ឯករាជ្យ, តែ ពាក្យ នេះ ក៏ វា មាន ន័យ ជា គតិយុត្ត គឺ ថា ជា បុគ្គល រស់ ក្នុង ព្រលាន នៃ ច្បាប់រដ្ឋ ដែល មាន ពាក្យ ថ្មី មួយ ទៀត ហៅ ថា « នីតិជន » គឺ ជា ជន មាន សិទ្ធិ និង ករណីយកិច្ច ជា ប្រជាជន នៅ ក្នុង ប្រជាជាតិ មួយ។

គួរ ដឹង ដែរ ថា តាំង ពី ស្រុកខ្មែរ មាន រដ្ឋធម្មនុញ្ញ ទី ១(១៩៤៧) មក ដល់ បច្ចុប្បន្ន អ្នក តែង ច្បាប់ ខ្មែរ យក ពាក្យ ទាំង ឡាយ ដែល បាន រៀបរាប់ ខាង លើ នេះ មក ប្រើ ខុសៗ គ្នា ទៅ តាម លទ្ធិ នយោបាយ ក្តី ទៅ តាម ឧបនិស្ស័យ (ចំណុចចិត្ត) ខ្លួន ក្តី។

ក្នុង របប រាជានិយម ទី ១ និង ទី ២ (របបបច្ចុប្បន្ន) គេ បាន ជ្រើស រើស យក ពាក្យ « ប្រជារាស្ត្រ » មក ប្រើ ដូច គ្នា និង របប សាធារណរដ្ឋ ដែរ (១៩៧០-១៩៧៥) តែ ចំណែក របប ខ្មែរ ក្រហម ពួក គេ បាន ជ្រើស រើស យក ពាក្យ « ប្រជាជន » មក ប្រើ ជំនួស ពាក្យ ប្រជារាស្ត្រ, ពាក្យ នេះ ក៏ ត្រូវ បាន របប ខ្មែរ កុម្មុយនិស្ត ក្រោម អាណាព្យាបាល វៀតណាម (១៩៧៩-១៩៩១)

យក មក ប្រើ បន្ត ពី របប ខ្មែរក្រហម ដែរ ។ ឯ ចំណែក ពាក្យ ប្រជាពលរដ្ឋ វិញ ហាក់ បី ដូច ជា ខ្មែរ យើង មិន សូវ នាំ គ្នា យក មក ប្រើ នៅ ក្នុង ឯកសារ ជា ផ្លូវការ, ប្រហែល ជា គេ យល់ ឃើញ ថា ពាក្យ នេះ វា មាន ទំហំ ជា « ពល » របស់ អ្នក កាន់ អំណាច សំរាប់ គេ យក មក ប្រើប្រាស់ ដូច ជា ឧបករណ៍ ឬ ដូច បសុសត្វ។

មក ដល់ ចំណុច នេះ, យើង លើក ជា សំណួរ សួរ ថា : អ្វី ទៅ ដែល ជា ប្រជារាស្ត្រ ?, ប្រជាពលរដ្ឋ ? ឬ ប្រជាជន ? នៅ ទី នេះ,យើង យក តែ ពាក្យ « ប្រជារាស្ត្រ » មក ប្រើ ចុះ ហើយ ជំរើស នេះ គឺ យើង គ្មាន ចំណង់ ថា ពាក្យ នេះ ជា ពាក្យ ល្អ ឬ មាន តម្លៃ ខ្ពស់ ជាង ពាក្យ ពីរ ទៀត នោះ ឡើយ ។ គឺ គ្រាន់ ជា ជំរើស មួយ តាម អាយុ ចាស់ ជាង ដោយ ប្រៀបធៀប នឹង ពាក្យពីរ ទៀត តែ ប៉ុណ្ណោះ។

## ប្រជារាស្ត្រ

មានទស្សនៈ ពីរ ស្តី ពី ប្រជារាស្ត្រ :

ទី១ : គេ ទុក ប្រជារាស្ត្រ ជា « សារព័ន នៃ សហគមន៍ ជាតិ », គឺ ជា ទស្សនៈ មួយ ដែល ប្រកប ដោយ ឧត្តមគតិ ដែល មាន សារជាតិ ជា « គតិ បណ្ឌិត រួមគ្នា », ជា « ប្រយោជន៏រួម » ដែល លោក រ៉ូសូរ (Rousseau), ទស្សនវិទូ បារាំង, លោក ហៅ ថា, ឆន្ទះ

ជា ទូទៅ ដែល មាន ប្រយោជន៍ តែ មួយ និង មាន ជំនឿ រួម គ្នា នៅ ក្នុង ឆន្ទៈ នេះ។

ទី២ : គេ ទុក ប្រជារាស្ត្រ ជា គំនរ នៃ មនុស្ស, ជា មនុស្ស គោកយ៉ាក ដែល ជា មនុស្ស ល្ងង់ខ្លៅ គិត តែ ខ្លួន ឯង, សាវ៉ា, រហូត ចាត់ ទុក ជា មនុស្ស ឃោឃៅ ទៅ ទៀត។ ទស្សនៈ នេះ ជា រូបភាព មួយ គួរ ឲ ខ្លាច តែ វា ក៏ បង្ហាញ នូវ ថាមពល នៃ ប្រជារាស្ត្រ ដែល ជា សេចក្តី ពិត រស់ រវើក មួយ ហើយ ក៏ ជា ការ បង្ហាញ នូវ រូបភាព ប្រវត្តិសាស្ត្រ របស់ ប្រទេស នីមួយៗ តាម អត្តភាព នូវ កម្លាំង នៃ ប្រជារាស្ត្រ (ដក ស្រង់ ចេញ ពី សៀវភៅ លោក P. Tavoillot, ជា នាយក នៃ ផ្នែក ទស្សវិជ្ជា ក្នុង សាលា ជាន់ ខ្ពស់ Collège de France (តើ អ្នក ណា ត្រូវ ដឹកនាំ ? Qui doit gouverner ?)

យើង សង្កេត ឃើញ ថា អ្នក ដឹងនាំ ខ្មែរយើង ក្នុង សម័យ សក្តិភូមិ មាន គំនិត ទុក ប្រជារាស្ត្រ ខ្លួន ឯង ប្រហាក់ ប្រហែល នឹង ទស្សនៈ ទី២ ខាង លើ នេះ គឺ គេ ទុក ប្រជារាស្ត្រ ជា មនុស្ស ខ្ជិល និង ល្ងង់ខ្លៅ ដែល គេ ច្រើន និយាយ ដោយ សង្កត់ ស ម្លេង មើល ងាយ ថា « ពួជ រាស្ត្រ វា ល្ងង់ខ្លៅ ណាស់ ហើយ ខ្ជិល ច្រអូស ទៀត ផង », ដូច្នេះ ត្រូវ ធ្វើ នយោបាយ ក្តៅ ទើប ពុត វា ឲ ខ្លាច បាក់ស្បាត ទើប អាច ងាយ ត្រួត បាន។

# ប្រជារាស្ត្រខ្មែរ និង នយោបាយ

មក ដល់ ចំណុច នេះ តម្រូវ ឲ យើង លើក យក « វប្បធម៌ នយោបាយ » មក បកស្រាយ ដើម្បី ឲ ស្រួល យល់ ពី ដំណួល ចិត្ត អ្នក ដឹកនាំ ខ្មែរ ចំពោះ ប្រជាពលរដ្ឋ ខ្លួន ឯង។

## វប្បធម៌ នយោបាយ

បើ យោង ទៅ តាម ទ្រឹស្តី នយោបាយ របស់ លោក Gabriel Almond, សង្គមវិទូ អាមេរិកាំង ម្នាក់, លោក បាន សរសេរ ថា : « បើ ថា « វប្បធម៌ សង្គម » មាន អត្ថន័យ ជា ឥរិយាបថ និង ជា អនុស្ថានប័ន (orientation) រួម នៃ បុគ្គល នីមួយៗ នៅ ចំពោះ មុខ សង្គម របស់ ខ្លួន មួយ ដែល មាន ក្បួន រស់នៅ ពិត ប្រកដ គឺ ច្បាស់ ជា មាន វប្បធម៌ នយោបាយ ផ្លែកៗ គ្នា ក្នុង លោក នេះ ព្រោះ ឥរិយាបថ និង អនុស្ថានប័ន រួម នៃបុគ្គល តែងតែ មាន ភាព ខុស ផ្លែក គ្នា ជា និច្ច ក្នុង ប្រព័ន្ធ សង្គម នីមួយៗ ហើយ បុគ្គល នីមួយៗ តែងតែ មាន ឥរិយាបថ និង អនុស្ថានប័ន ខុស ផ្លែក ពី បុគ្គល ម្នាក់ ទៀត នៅ ចំពោះ មុខ ប្រព័ន្ធ នយោបាយ មួយ។

យើង អាច បក ស្រាយ គំនិត នេះ ជា គំនិត សាមញ្ញ ថា : ប្រជារាស្ត្រ មាន វប្បធម៌ នយោបាយ មួយ ក្នុង ប្រព័ន្ធសង្គម តែ បុគ្គល ម្នាក់ៗ មាន វប្បធម៌ នយោបាយ របស់ ខ្លួន ក្នុង ប្រព័ន្ធ នយោបាយ បើ និយាយ ឲ ស្រួល យល់ ទៅ ទៀត ដោយ យក ឧទាហរណ៍ មក បង្ហាញ គឺ ថា : ប្រជារាស្ត្រ ខ្មែរ ជា អ្នក រាជានិយម តែ ខ្មែរ ម្នាក់ៗ អាច មិន ស្រឡាញ់ វិធី ដឹកនាំ នៃ របប

រាជានិយម ផ្តាច់ការ ឬ សក្តិភូមិ។ ក្នុង គំនិត នេះ ហើយ ដែល សហរដ្ឋអាមេរិក ក្រោយ ពី ឈ្នះ សង្គ្រាម លើប្រទេស ជប៉ុន ក្នុង សង្គ្រាម លោក លើកទី២ បាន ទុក ព្រះចៅ អធិរាជជប៉ុន អោយ នៅ សោយរាជ្យ ដដែល ព្រោះ អាមេរិកាំង យល់ ឃើញ ថា ប្រជារាស្ត្រ ជប៉ុន នៅ ស្រឡាញ់ និង គោរព ព្រះចៅអធិរាជ តែ អាមេរិកកាំង បាន ដូរ របប នយោបាយ ជប៉ុន ដោយ គេ យល់ ឃើញ ថា ជនជាតិ ជប៉ុន ម្នាក់ អាច មាន គំនិត ខុស គ្នា ទៅ លើ របបន យោបាយ ចាស់ ដូច្នេះ អាមេរិកាំង ទុក លទ្ធភាព ឲ ប្រជារាស្ត្រ ជប៉ុន ធ្វើ ការជ្រើសរើស តាម លទ្ធិ ប្រជាធិបតេយ្យ សេរី នូវ វិធី ដឹកនាំ នយោបាយ មួយ ថ្មី សំរាប់ ប្រទេស ជប៉ុន។

ក្នុង វប្បធម៌ នយោបាយ នីមួយៗ មាន ទំហំ បីយ៉ាង ហើយ វា ប្រែប្រួល ទៅ តាម ប្រទេស ឬ តាម ប្រព័ន្ធសង្គម នីមួយៗ។ ទំហំ ទាំង បី យ៉ាង នោះ មាន ដូច តទៅ :

១. ទំហំ « ការឃើញស្គាល់ » (cognitif) ជា ឧទាហរណ៍ : ទំហំ នៃ វប្បធម៌ នយោបាយ របស់ ពួក ខ្មែរក្រហម គឺ អំពើ ប្រល័យ ពូជ សាសន៍ ប្រជារាស្ត្រ របស់ ខ្លួន ឯង។

២. ទំហំ « ការសំដែង ចិត្ត មិត្តភាព » (affectif) ជា ឧទាហរណ៍ : ទំហំ នៃ វប្បធម៌ នយោបាយ នៃ លទ្ធិ ប្រជាធិបតេយ្យ សេរី គឺ ភាតរភាព ក្នុងសង្គម។

៣. ទំហំ « ការវិវឌ្ឍន៍ » (évolutif) ជា ឧទាហរណ៍ : វប្បធម៌ នយោបាយ នៃ ប្រទេស ដែល គោរព សិទ្ធិ មនុស្ស តែង តែ មាន ការវិវឌ្ឍ ទៅ រក លិទ្ធិ ប្រជាធិបតេយ្យ សេរី ជា និច្ច ហើយ ការវិវឌ្ឍន៍ នេះ វា តែងតែ មាន ទៅវិញ ទៅមក។

ម្យ៉ាង ទៀត គេ បែង ចែក វប្បធម៌ នយោបាយ ជា ក្រុម ធំ បី យ៉ាង :

១. វប្បធម៌ នយោបាយ ជា បក្សពួក[1], ប្រជារាស្ត្រ មាន វប្បធម៌ បែប នេះ មិន សូវ មាន គំនិត ជាតិនិយម នោះ ទេ ហើយ មិន សូវ ស្គាល់ ផង នូវ ន័យ របស់ « រដ្ឋ ប្រជាជាតិ »។ ក្នុង វប្បធម៌ នេះ គេ រស់ ជា ក្រុម, ស្គាល់ តែ ភូមិ របស់ ខ្លួន, រស់ ជា បក្សពួក ឬ ជា ជាតិពន្ធុ តែ ប៉ុណ្ណោះ។

២.វប្បធម៌ នយោបាយ ជា ប្រជារាស្ត្រ រង់ចាំ « ជនុបត្ថម្ភក[2] » (អ្នក ទំនុក បម្រុង ដល់ ប្រជារាស្ត្រ), ប្រជារាស្ត្រ មាន វប្បធម៌ បែប នេះ ជា ប្រជារាស្ត្រ ស្គាល់ ច្បាស់ អត្ថិភាព របស់ ខ្លួន តែ រស់ ជា អកម្ម រង់ចាំ តែ អំណាចរដ្ឋ, អង្គការ ដ៏ ទៃ ទៀត ជួយ ឧបត្ថម្ភ ក្នុង ការរស់នៅ របស់ ខ្លួន តែផ្ទុយទៅវិញ គេ មាន ការ បារម្ភណ៍ ជានិច្ច ខ្លាច អំណាចរដ្ឋ រិប ជាន់ សម្បត្តិ ឬ រំលោភ

---

[1] វប្បធម៌ នយោបាយ ជា បក្សពួក : culture politique paroissiale.

[2] វប្បធម៌ នយោបាយ ជា ប្រជារាស្ត្រ រង់ចាំ « ជនុបត្ថម្ភក » : culture politique de participation.

លើ សិទ្ធិ របស់ខ្លួន។ ប្រជារាស្ត្រ បែប នេះ ជា ប្រជារាស្ត្រ រស់នៅ ក្រៅ ប្រព័ន្ធ នយោបាយ ជាតិ។

៣. វប្បធម៌ នយោបាយ ជា ការ ចូល រួម ចំណែក, ប្រជារាស្ត្រ ជា និតិជន ស្គាល់ សិទ្ធិ និង មធ្យោបាយ របស់ ខ្លួន សំរាប់ ធ្វើស ម្លាត តាម លទ្ធិ ប្រជាធិបតេយ្យ សេរី ទៅ លើ ប្រព័ន្ធ នយោបាយ ឲ គេ ដូរ ឬ កែទម្រង់ នយោបាយ ទៅ តាម ចំណុចចិត្ត ដែល ខ្លួន ចង់ បាន។ ប្រជារាស្ត្រ បែប នេះ ជា ប្រជារាស្ត្រ ចូល រួម យ៉ាង សកម្ម ក្នុង នយោបាយ ជាតិ, គេ ទុក ខ្លួន ឯង ជា ម្ចាស់ នៃ អំណាចរដ្ឋ ដែល មាន ការធានា ពី ទេសធម៌ (ច្បាប់សំរាប់ប្រទេស) គឺ រដ្ឋធម្មនុញ្ញ។

## វប្បធម៌ នយោបាយ នៃ ប្រជារាស្ត្រខ្មែរ

យើង សាកល្បង យក ទ្រឹស្តី ខាង លើ នេះ មក ឆ្លុះ មើល វប្បធម៌ នយោបាយ នៃ ប្រជារាស្ត្រខ្មែរ :

ក្នុង សម័យ បុរាណ ជា ពិសេស ក្នុង សម័យ អង្គរ ដែល ប្រទេស ខ្មែរ មាន សេចក្តី រុងរឿង ជា មហា អំណាច នៅ ក្នុង ដំបន់ អាស៊ី អាគ្នេយ៍, ក្នុង រូបភាព នេះ នាំ យើង ចោទ ជា សំនួរ ថា, តើ វប្បធម៌ នយោបាយ នៃ ប្រជារាស្ត្រ ខ្មែរយើង ជា វប្បធម៌ បែប ណា? តើ ប្រជារាស្ត្រ ខ្មែរយើង មាន ចំណែក និង បាន ចំណែក ដែរ ឬ ទេ ពី កិត្តិគុណ នៃ ប្រទេសជាតិ ខ្លួននេះ ?

បើ សិន ជា យើង គ្រាន់ តែ យក សំណង់ ប្រាសាទ ដ៏ វិចិត្រ ទាំងឡាយ និង ផ្ទៃក្រឡា ទឹកដី ធំ របស់ ស្រុកខ្មែរ មក ធ្វើ ជា គោល នៃ ហេតុផល នៃ សេចក្តី រុងរឿង នេះ, យើង ធ្វើ អនុមាន បាន ថា, ប្រជារាស្ត្រ ខ្មែរ មាន វប្បធម៌ នយោបាយ ខ្ពង់ខ្ពស់ ទើប អាច ជាតិខ្មែរ មាន ការថ្កុំថ្កើង បាន។ ការយល់ ឃើញ នេះ គឺ ឈរ លើ ទសនទ្សនៈ សម្ភារនិយម, តែ យើង ដឹង ដែរ ថា ទស្សនៈ នេះ មិន អាច បង្ហាញ ការពិត ទាំង អស់ នោះ ឡើយ, ឧទាហរណ៍, ដូច ជា យើង ឃើញ ភូមិ គ្រឹះ ល្អៗ ដុះ ពាស ពេញ ទីក្រុង ភ្នំពេញ, ម៉ុង ខ្មោច ចិន យួន ធំៗ ដុះ ពាស ពេញ នៅ ស្រុកខ្មែរ បច្ចុប្បន្ន នេះ, តើ យើង អាច ធ្វើ អនុមាន បាន ថា ស្រុកខ្មែរ ជា ប្រទេស ថ្កុះថ្កើង បាន ដែរ ឬ ទេ ? ក៏ ដូច គ្នា ក្នុង សម័យ សង្គម រាស្ត្រនិយម, យើង ឃើញ មាន ដុះ មហា វិទ្យាល័យ ដូច ដុះ ស្មៅ ក៏ យើង ពុំ អាច ធ្វើ អនុមាន បាន ថា ស្រុកខ្មែរ ជា ប្រទេស មួយ ដែល ប្រជារាស្ត្រ មាន កំរិត ការចេះដឹង ដ៏ ខ្ពង់ខ្ពស់ នោះ ឡើយ។

គួរ លើក យក ពាក្យ អរិយធម៌ មក ពិចារណា ដែរ, ក្នុង ពាក្យ អារ្យធម៌ នេះ, តាម ប្រវត្តវិទូ ល្បីល្បាញ មួយ ចំនួន, ដូចលោក Fernand Braudel គាត់ បាន សរសេរ ក្នុង សៀវភៅ[3] ថា « ប្រវត្តិវិទូ ខ្លះ តែង មាន ចំណង់ ចែក ពាក្យ ពីរ ដាច់ គ្នា គឺ ពាក្យ អារ្យធម៌ និង វប្បធម៌ : តាម លោក Alfred Weber, អារ្យធម៌ គឺ

[3] Grammaire des civilisations.

# ប្រជារាស្ត្រខ្មែរ និង នយោបាយ

គ្រាន់ ជា ការចេះដឹង ជា ទូទៅ អំពី វិស័យ បច្ចេកទេស និង របៀប ប្រើប្រាស់ ដែល ជា ការសម្រាំង មួយ នៃ មធ្យោបាយ របស់ មនុស្ស សំរាប់ ការរស់នៅ ក្នុង ធម្មជាតិ, ចំណែក ឯ ពាក្រ « វប្បធម៌ » វិញ គឺ ជា គោល ធម្មនិយាម (Principes normatifs) នៃ « តម្លៃ », « ឧត្តមគតិ » របស់ សង្គម មនុស្ស ដែល គេ ហៅ ថា « សតិ ឬ ព្រលឹង » សង្គម។

ដើម្បី ឆ្លុះ មើល វប្បធម៌ នយោបាយ នៃ ប្រជារាស្ត្រខ្មែរ ក្នុង គ្រប់ សម័យ បុរាណ ខ្មែរ, គួរ យើង ពិនិត្យ មើល វត្ថុ ធាតុ ពីរ : ធាតុសង្គម និង ធាតុ ប្រព័ន្ធ នយោបាយ, ធាតុ ទាំង ពីរ នេះ, ប្រវត្តិវិទូ ល្បីៗ ឈ្មោះ មិន សូវ លើក យក មក ធ្វើ ជា ប្រធាន បទ សិក្សា នោះ ឡើយ ព្រោះ វា ជា ប្រធានបទ ពិសិដ្ឋ ដែល ប៉ះ ពាល់ មិន បាន (វិសិដ្ឋ) ដោយសារ វា មាន ធាតុន យោបាយ អាច នាំ ឲ ប៉ះពាល់ និង ខូច ប្រយោជន៏ ដល់ របប រាជានិយម និង អាជ្ញា ធរ បារាំង ក្នុង ជំនាន់ អាណាព្យាបាល បារាំង។ យើង ត្រូវដឹង ថា នៅ ស្រុកខ្មែរ, ប្រវត្តិវិជ្ជា ជា វិស័យ ទុក សំរាប់ តែ អ្នក ដឹកនាំ, គេ សរសេរ ទុក សំរាប់ ធ្វើ ការឃោសនា នយោបាយ តែ ប៉ុណ្ណោះ, អ្វី ដែល ល្អ សំរាប់ គេ, គេ នាំ គ្នា សរសេរ ទុក ហើយ អ្វី ដែល ជា អំពើ អាក្រក់, គេ នាំ គ្នា បំភ្លេច ចោល ហើយ ហាម មិន ឲ លើក មក និយាយ ទៀត ផង, ឧទាហរណ៏ ដូច ក្នុងបច្ចុប្បន្ន នេះ អ្នក ដឹកនាំ ដើម្បី ប្រយោជន៏ ដែល ឋិត នៅ តែ មួយ ស្របក់ របស់ គាត់, ពួក គាត់ នាំ គ្នា សរសេរ

# ប្រវត្តិសាស្ត្រខ្មែរ និង នយោបាយ

ប្រវត្តិហេតុ របស់ សម្ដេច សីហនុ ខុស ពី សេចក្ដីពិត ឆ្ងាយណាស់, ហេតុ នេះ ឯង ហើយ, តម្រូវ ឲ្យ អ្នក អាន ឬ អ្នក សិក្សាប្រវត្តិសាស្ត្រ នយោបាយ ខ្មែរ លើ ចំណេរ ទាំងឡាយ ឲ្យ មាន ការប្រុងប្រយ័ត្ន កុំ មើល តែ នឹង ភ្នែក ហើយ រីករាយ (enchanter) ក្នុង ល្បិច រក ប្រយោជន៍ របស់ អ្នក និពន្ធ។ យើង និយាយ នេះ មិន មែន យើង ចេះ តែ មាន ការគិត មមៃ ថា គ្រប់ ប្រវត្តិវិទូ សរសេរ អំពី ប្រវត្តិសាស្ត្រ សុទ្ធ តែ មាន គោល បំណង បំរើ ប្រយោជន៍ នយោបាយ នោះ ឡើយ តែ ជួន កាល គេ សរសេរ ដោយ ផ្អែង ទាំង ស្រុង ទៅ លើ ឯកសារ ដែល អ្នក កាន់អំណាច គេ សរសេរ ទុក សំរាប់ កេរ្តិ៍ ឈ្មោះ ជា ចិរកាល របស់ គេ។ ឯកសារ បែបនេះ គេ ច្រើន  ទុក ជា វត្ថុ ជា ប្រវត្តិសាស្ត្រ, តែ មិន មែន ជា ប្រវត្តិហេតុ បង្ហាញ  ការពិត នោះ ឡើយ។ ដូច្នេះ វិស័យ ប្រវត្តិសាស្ត្រ ជា ពិសេស ប្រវត្តិសាស្ត្រ នយោបាយ ជា វិស័យ មួយ នៅ ស ស្អាត សំរាប់ អ្នក ប្រវត្តិសាស្ត្រ ខ្មែរ បច្ចុប្បន្ន នេះ ក្ដី ក្នុង អនាគតកាល ក្ដី មាន លទ្ធភាព ច្រើន ធ្វើ ការរុករក សេចក្ដីពិត សំរាប់ ប្រជាជាតិខ្មែរ។ យើង ត្រូវ ដឹង ថា បច្ចុប្បន្ន នេះ អ្នក ដឹកនាំ វៀតណាម គេ កំពុង កាន់ ដៃ អ្នក ដឹកនាំ ខ្មែរ នាំ សរសេរ តាម គំនិត របស់ គេ អំពី ប្រវត្តិសាស្ត្រ នយោបាយ មួយ ដែល គេ ដាក់ ចំណងជើង ថា : « ការទំនាក់ទំនង ពិសេស រវាង វៀតណាម និង ខ្មែរ ចាប់ តាំង ពី ឆ្នាំ ១៩៣០ ដល់ ឆ្នាំ ២០០៥ »។ គោល បំណង នេះ គួរ ខ្មែរយើង ទុក ជា ភេរវសញ្ញា (alerte) និង ជា គ្រោះ ថ្នាក់ មួយ សំរាប់ ជាតិខ្មែរ។

ត្រឡប់ មក និយាយ វិញ អំពី វត្ថុធាតុ ពីរ សំខាន់ គឺ ធាតុ សង្គម ខ្មែរ និង ប្រព័ន្ធ នយោបាយ ខ្មែរ។ បើ យើង បាន អាន ប្រវត្តិសាស្ត្រ ខ្មែរ ដោយ យក បញ្ញា ជា រស្មី សំរាប់ ឆ្លុះ មើល ប្រវត្តិហេតុ យើង ឃើញ ច្បាស់ ថា សង្គម ខ្មែរ មុន ក្រោយ សម័យ អង្គរ និង នៅ ក្នុង សម័យ អង្គរ ក្តី មាន ធាតុ ជា សង្គម សក្តិភូមិ។ ដូច្នេះ គួរ យើង ចោទ ជា សំណួរ ថា សង្គម សក្តិភូមិ ខ្មែរ ជា សង្គម បែប ណា ?

តាម ការសិក្សា របស់ លោក សាស្ត្រាចារ្យ វ៉ាន់ឌី កាអុន ដែល មាន ចំណង ជើង ថា « សង្គម សក្តិភូមិ ខ្មែរ នៅ ក្នុង រឿង ទុំ ទាវ » (រឿង ទុំទាវ ជា រឿង មាន កើត ឡើង ក្នុង សត្វវត្ស ទី១៦ ក្នុង រជ្ជកាល ព្រះបាទ បរមរាជា (១៥៦៨-១៥៧៦) សម័យ លង្វែក)។ បើ យើង អាន ការសិក្សា របស់ លោក វ៉ាន់ឌី កាអុន (លោក ជា ទុល្លកៈ ជន[4] ខ្មែរ ម្នាក់) សរសេរ ឡើង ក្នុង ឆ្នាំ ១៩៧១, យើង អាច ដក ស្រង់ បាន នូវ វត្ថុធាតុ ធំបី ដែល យើង យល់ ឃើញ ថា ជា គ្រិះ នៃ សង្គម សក្តិភូមិ ខ្មែរ។

១. ដំបូន្មាន, លោក វ៉ាន់ឌី កាអុន លោក សរសេរ ថា : « ដំបូន្មាន សំដៅ ទៅ មេរៀន ឬ អកប្បកិរិយា ដែល មនុស្ស ម្នាក់ៗ នៅ ក្នុង សង្គម, ត្រូវ គោរព ធ្វើ តាម, ដើម្បី ថែ រក្សា ទំនៀម ទម្លាប់ ឲ បាន គង់វង់ ល្អ។ បើ មនុស្ស ណា ម្នាក់ មិន គោរព ទំនៀម ទម្លាប់ នោះ ទេ គេ ទុក មនុស្ស នោះ ជា

[4] ទុល្លកៈ ជន : ជន កម្សត់ក បាន។

មនុស្ស ពាល ដែល គេ ឈប់ រាប់អាន ទៀត។ ដោយ ខ្លាច ការ ដាក់ ទោស នេះ, មនុស្ស គ្រប់ រូប ត្រូវ សង្កម របស់ ខ្លួន កាច់ ឲ បាក់ ជា ផ្នត់ ស្រេចៗ តែ ម្ដង, ការកាច់ ឲ បាក់ ជា ផ្នត់ ដូច្នេះ គេ ហៅ ថា ការអប់រំ »។

២. ការអប់រំ, ក្នុង វិស័យ នេះ លោក វ៉ាន់ឌី កាអុន សរសេរ ថា : « ដើម្បី ឲ យល់ នូវ កតព្បកិច្ច នេះ, អ្នក ទូន្មាន ខ្មែរយើង តែង ប្រដៅ ថា : « ចូល ស្ទឹង តាម បទ ចូល ស្រុក តាម ប្រទេស »។ លុះ មនុស្ស ម្នាក់ៗ សុខចិត្ត ឲ គេ កាច់ ឲ គេ អប់រំ ដោយ ស្រួលបួល ហើយ (ដោយ មិន ដឹង ខ្លួន) អ្នក ដែល មាន ប្រជ្ញា ជាង គេ ក៏ តាំង តែ រំលោភ មក លើ អ្នក មាន ប្រជាជ្ញា តិច ជាង ខ្លួន។ ដើម្បី ការពារ ផល ប្រយោជន៍ របស់ គេ, អ្នក មាន ប្រជ្ញា ទាំង នោះ ក៏ កាន់ តាក់តែង មេរៀន ចរិយាសាស្ត្រ ឬ ដំបូន្មាន ផ្សេងៗ ដោយ ខ្លួន ឯង។ ឧទាហរណ៍ : « ខ្លួន ទាប កុំ គោង, ដៃ ខ្លី កុំ ឈោង ស្រវា ឱប ភ្នំ » ; « ពង មាន់ កុំជល់ នឹង ថ្ម » ; « ទំ មិន ធំ ជាង នៀល »។ ពាក្យ ប្រដៅ ទាំង ឡាយ ខាង លើ នេះ ជា ពុម្ព នៃ ការអប់រំ « បណ្ដារាស្ត្រ ខ្មែរយើង នៅ សម័យ សក្តិភូមិ។

៣. ការស្មោះត្រង់, លោក វ៉ាន់ឌី កាអុន បាន បង្ហាញ ចំណុច នេះ ដូច ត ទៅ : « រីឯ ការស្មោះត្រង់ នោះ គឺ ស្មោះត្រង់ គ្មាន ល័ក្ខខ័ណ្ឌ, បុណ្យស័ក្តិ បុណ្យ ផង កើត ទៅ ដោយសារ ការស្មោះ ត្រង់ នេះ។ ទោះ បី ចេះ ឬ មាន ប្រជ្ញា ប៉ុណ្ណា ក្តី បើ មិន ព្រម

លក់ ខ្លួន ទៅ ឲ អ្នក មាន អំណាច រិទ្ធិ បារមី ទេ ក៏ បុណ្យ ស័ក្តិ នោះ ពុំ អាច គង់វង់ បាន ដែរ។

ប្រសិន បើ បាន បុណ្យស័ក្តិ ហើយ ត្រឡប់ ជា ឆ្មើង ទៅ វិញ ក៏ បុណ្យ ស័ក្តិ នោះ ពុំ អាច គង់វង់ បាន ដែរ។ ឧទាហរណ៍ : « បើ បាន ងារ ស័ក្តិយស ចិត្ត ឲ ស្មោះ នឹង មហាក្សត្រ, បើ ចង់ គង់ សម្បត្តិ ច្បាប់ លោកថា កុំ សូវ ចាយ »។

លោក វ៉ាន់ឌី កាអុន បាន សន្និដ្ឋាន ដូច្នេះ « ដោយ ច្បាប់ ចរិយាសាស្ត្រ សង្គម សក្តិភូមិ នោះ មាន លក្ខណៈ តឹងតែង ដូច្នេះ, លំនាំ នៃ ការរស់នៅ ក៏ យោល ទៅ តាម ច្បាប់ (éthique) នោះ ដែរ »។

យោង ទៅ លើ គ្រឹះ សង្គម សក្តិភូមិ ខាង លើ នេះ, អាច ឲ យើង ធ្វើ ការស្មាន បាន ថា, ប្រជារាស្ត្រ ខ្មែរយើង រស់នៅ ក្នុងសង្គម សក្តិភូមិ ជា ប្រជារាស្ត្រ ស្តាប់ បង្គាប់ អ្នក កាន់ អំណាច ណាស់, មាន វប្បធម៌ នយោបាយ ជា ការរង់ចាំ ជនុបត្ថម្ភក, ដូច្នេះ គាត់ ខ្លាច ផង និង ស្មោះត្រង់ ផង នឹង អ្នក កាន់អំណាច ព្រោះ គាត់ ត្រូវការ ជា ចាំបាច់ នៃ អំណាច អ្នក ដឹកនាំ ក្នុង ការរស់នៅ ជា រៀងរាល់ ថ្ងៃ របស់គាត់។ វប្បធម៌ នេះ ជា គ្រឿង ទប់ នូវ សេចក្តី ចម្រើន នៃ សង្គម នយោបាយ។ ការវិវឌ្ឍន៍ របស់ វា គឺ ស្ទើរ តែ ឋិត នៅ ក្នុង និច្ចលភាព, ដូច្នេះ ឯង ហើយ បាន ជា ខ្មែរយើង តែងតែ សួរ ខ្លួន ឯង ថា : ចុះ ហេតុ អ្វី បាន ជា នៅ ស្រុកខ្មែរ ពិបាក នឹង អនុវត្ត លទ្ធិ ប្រជាធិបតេយ្យ

# ប្រជារាស្ត្រខ្មែរ និង នយោបាយ

សេរី? ហើយ អ្នក ដឹងនាំ មិន ថា ជា ពូជ ស្តេច ឬ រាស្ត្រ ក្តី ពួក គាត់ ឥត មាន ដូរ របៀប ដឹងនាំ ឲ ស្រប ទៅ នឹង សម័យ ថ្មី។ ប្រជារាស្ត្រ ខ្មែរ ក្នុង សង្គម សក្តិភូមិ ជា ពល, កម្លាំងបាយ របស់ អ្នក កាន់ អំណាច ដែល ខ្មែរយើង មាន ទម្លាប់ ហៅ ថា « ប្រជាពលរដ្ឋ » ឬ ជា ពល សំរាប់ អ្នក ដឹកនាំ ផ្ញើ ភារិកម្ម បាន (កេណ្ឌ) សំរាប់ បំរើ ប្រយោជន៍គេ ហើយ គេ ទុក ភារិកម្ម នេះ ជា ពន្ធ ត្រូវ បង់ ខាន មិន បាន ឲ គេ, តែ ពន្ធ នេះ ជា ពន្ធ គ្មាន បដិភាគ នោះ ឡើយ។

ប្រជារាស្ត្រខ្មែរ គាត់ រស់ ក្នុង ភូមិ តូចៗ ជា គ្រួ ជា ញាតិ ប្រកប ដោយ សុខដុមភាព ក្នុង ជនាបទ (បែប បទ ក្នុងភូមិ)។ គោល ជីវិត របស់ គាត់ គឺ សេចក្តីសុខ ក្នុង គ្រួនេះ ដែល ជា ផ្នត់ គំនិត ដែល គាត់ ទទួល ពី ការអប់រំ, ដូច្នេះ ខ្មែរម្នាក់ៗ មិន ដែល ហ៊ាន មាន គំនិត អ្វី ខុស ពី គំនិត គ្រួ របស់ខ្លួន ព្រោះ ខ្លាច នាំ ទុក ឲ ញាតិ ខ្លួន។ ដំបូន្មាន នៃ គ្រួ ខ្មែរ គឺ « កុំ ខំហួស វាសនា, កុំ ចរចា ចោលច្បាប់, កុំ ប្រឹង ចោល កណ្តាប់, កុំ បន្លំ ចោល ខ្នាត » (ច្បាប់ ហៃ មហាជន), ក្នុង ផ្នត់ គំនិត នេះ នាំ រលុប អ្វីៗ ដែល មាន លើស ពី ភូមិ និង គ្រួ របស់ គ្រួ ខ្មែរ នីមួយៗ។ អវត្តមាន នៃ សញ្ញាណ របស់ ប្រជាជាតិ មាន ជាក់ ស្តែង ក្នុង សង្គម ខ្មែរ ដែល ខ្មែរយើង តែង និយាយ ថា : « រឿង ប្រទេស ជាតិ ជា រឿង របស់ ស្តេច ទុក ឲ ព្រះអង្គ ដោះ ស្រាយ ទៅ » ឬ « ខ្លួន មួយ ពុំ អាច ទ្រ ផែន ដី បាន នោះ ទេ » ឬ « ទ

# ប្រជារាស្ត្រខ្មែរ និង នយោបាយ

ទេៗ ទៅ យក ជ័រ មក ត្បៀត ក្លៀក »។ យើង ដឹង ថា ដំបូន្មាន បែប នេះ ឥត អាច ឲ ផល អ្វី ដល់ ប្រជាជាតិ នោះ ឡើយ, វា នាំ អោយ ប្រជារាស្ត្រ លះបង់ សិទ្ធិ ខ្លួន ឲ អ្នក កាន់ អំណាច ទាំង ស្រុង, ហេតុ នេះ ឯង ហើយ បាន ជា យើង ឃើញ ក្នុង សង្គម សក្តិភូមិ ខ្មែរ ឬ សង្គម ខ្មែរ តែ ម្តង, ការទាក់ទងគ្នា រវាង អ្នក កាន់ អំណាច និង ប្រជារាស្ត្រ វា មាន ភាព ជា ទំនាក់ ទំនង បែប « ម្ចាស់ និង ខ្ញុំ », « អ្នក ធំ និង អ្នក តូច », « អំណាច និង ប្រតិបាប្ធន៍ (ការចេះ ស្តាប់ បង្គាប់)។

ការទំទំនាក់ទំនង នេះ ជា ការបង្ហាញ នូវ លក្ខណៈ ប្រព័ន្ធ នយោបាយ ខ្មែរ ថា ជា ប្រព័ន្ធ សក្តិភូម៌ ឬ ផ្តាច់ការ។ ហើយ ប្រព័ន្ធ នេះ វា នៅ រស់ រវើក ក្នុង សង្គម ខ្មែរ បច្ចុប្បន្ន នេះ, ដូច្នេះ វា ហាក់ បី ដូច ជា សង្គម នយោបាយ ខ្មែរ ឥត មាន ការវិវឌ្ឍន៍ អ្វី បន្តិច សោះ តាំង ពី បុរាណ កាល រហូត មក ដល់ ឥឡូវ នេះ។ និច្ចលភាព នេះ នាំ ឲ យើង ធ្វើ អនុមាន ថា ប្រជារាស្ត្រខ្មែរ និង នយោបាយ ហាក់ បី ដូច ជា ធាតុ ពីរ មិន រលាយ ចូល គ្នា បាន ដូច ទឹក និង ប្រេង, តែ ខ្មែរយើង ដឹង ច្បាស់ ណាស់ ថា ទោះ បី ប្រេង វា អណ្តែត លើ ទឹក ក៏ ដោយ, តែ បើ យើង យក ភ្លើង ទៅ ដុត វា ច្បាស់ ជា នឹង ឆេះ ធ្លូ ឡើង លើ ទឹក ហើយ នឹង ធ្វើ ឲ ទឹក មាន កំដៅ ពុះ ជា ពុំ ខាន។ យើង ត្រូវ គិត ថា ទឹក ក៏ ដូច ជា ប្រជារាស្ត្រ, ប្រេង ក៏ ដូច ជា

នយោបាយ, ទោះ បី វា មិន រលាយ ចូល គ្នា តែ វា មាន បដិការ ជា មួយ គ្នា ដូច បាន រៀបរាប់ ខាង លើ នេះ។

យើង ត្រូវ ដឹង ដែរ ថា បើ ប្រជារាស្ត្រ ខ្មែរ មិន ចូល រួម ចំណែក ក្នុង នយោបាយ គឺ នយោបាយ វា ច្បាស់ ជា នឹង ធ្វើ ប្រឆាំង នឹង ប្រយោជន៍ ប្រជារាស្ត្រ ជា ពុំខាន ព្រោះ ថា នយោបាយ ជា អំណាច ហើយ អំណាច តែងតែ ៗ ចំណង់ អ្នក កាន់ អំណាច ស្វែង រក ចំណេញ ដល់ ខ្លួន ជា និច្ច បើ សិន អំណាច នោះ គ្មាន អ្វី សំរាប់ ទប់ ទេ, ចំណង់ នោះ ច្បាស់ ជា រីក ធំ ជា ពុំ ខាន។

បច្ចុប្បន្ន នេះ ប្រជារាស្ត្រខ្មែរ មាន មធ្យាបាយ គ្រប់គ្រាន់ សំរាប់ ចូល រួម ជា សកម្ម ក្នុង នយោបាយ, មធ្យោបាយ នោះ មាន ច្បាប់ជាតិ ផង ច្បាប់ អន្តរជាតិ ផង និង ច្បាប់ ធម្មជាតិ ផង, រឿង សំខាន់ នោះ គឺ សេចក្តី ក្លាហាន ក្នុង ការ ធ្វើ នយោបាយ ដើម្បី ការពារ ខ្លួន ឯង ផង និង ការពារ ជាតិ ផង តែ ប៉ុណ្ណោះ។ ឧទាហរណ៍ : មាន ច្រើន ដូច យ៉ាង បើ លោក អូបា៉ មា,ប្រធានាធិបតី សហរដ្ឋអាមេរិក គេ បង្ហាញ ការ មិន គាំទ្រ របស់ គេ ចំពោះ នយោបាយខ្មែរ បច្ចុប្បន្ន នៅ ចំពោះ មុខ អ្នក ដឹកនាំ កំពូល ខ្មែរ មិន មាន ន័យ ថា ខ្មែរយើង នៅ តែ ដេក រង់ចាំ អន្តរាគមន៍ អាមេរិកាំង ដើម្បី ធ្វើ សម្ពាត ទៅ លើ រដ្ឋាភិបាលខ្មែរ នោះឡើយ គឺ ខ្មែរយើង ទេ ដែល ត្រូវ ងើប ឈរ ព្រម គ្នា ឡើង ដើម្បី ធ្វើ សម្ពាត ទៅ លើ អ្នក ដឹកនាំ ខ្លួន ៗ

ខ្លាំង សិន ទើប អាច មាន សម្លាត ជា ជំនួយ ពី កម្លាំង អន្តរជាតិ។

ឧទាហរណ៍ មួយ ទៀត, បើ ប្រទេស លោក សេរី គេ ប្រាប់ លោក សម រង្ស៊ី និង កឹម សុខា ថា គេ ចង់ ឲ្យ ស្រុកខ្មែរ ដោះ ដូរ អ្នក ដឹកនាំ តាម ការបោះឆ្នោត ដោយ សេរី និង យុត្តិធម៌ មិន មែន មាន ន័យ ថា ឲ្យ អស់ លោក ចូលរួម ការបោះឆ្នោត នោះ ឡើយ គឺ គេ ចង់ ឲ្យ អស់ លោក ធ្វើ ពហិការ បើ ការបោះឆ្នោត នោះ វា គ្មាន « សេរី និង យុត្តិធម៌ »។ ក្នុង ចំណុច នេះ យើង ឃើញ ថា មិន មែន តែ ប្រជារាស្ត្រ ខ្មែរ គាត់ មិន ចូល រួម ធ្វើ នយោបាយ ដូច អ្នក ដឹកនាំ គណៈបក្ស ប្រឆាំង ក៏ គាត់ មិន ច្បាស់ ជា ធ្វើ នយោបាយ ដែរ ព្រោះ យើង ឃើញ ការធ្វើ របស់ ពួក គាត់ ជា ដំណើរ សុនទ្រុន ណាស់, សួរ ថា តើ អាច ទទួលសុផាត ផល (ផលល្អ) បាន ដែរ ឬ ទេ ក្នុង ដំណើរ សាញ របស់ ពួក គាត់ នេះ។ យើង ឥត មើល ឃើញ អ្វី ទាំង អស់ ថា ពួក គាត់ ចង់ ធ្វើ អ្វី នោះ មក ដល់ ថ្ងៃ នេះ ហើយ តើ គាត់ អាច ទៅ ប្រមូល ប្រជារាស្ត្រ បែប ណា។ ចំណែក លោក សម រង្ស៊ី សព្វ ថ្ងៃ គាត់ ចាំ តែ មួយគត់ គឺ ការអនុញ្ញាត ពី លោក ហ៊ុន សែន ឲ្យ គាត់ ចូល  ស្រុក តែ ប៉ុណ្ណោះ, បើ មាន មែន, គាត់ អាច នឹង បោះ បង់ ឧត្តមគតិ គាត់ ទាំង អស់ សំរាប់ ដូរ នឹង ការវិលត្រ ចូល ស្រុក  វិញ តែ ប៉ុណ្ណោះ។ យើង និយាយ នេះ គឺ គ្មាន គំនិត អ្វី ចង់ មើល ងាយ លោក សម រង្ស៊ី នោះ ឡើយ,តែ យើង មើល

# ប្រជារាស្ត្រខ្មែរ និង នយោបាយ

ឃើញ ថា លោក សម រង្ស៊ី កំពុង ចាញ់បោក គូកន គាត់ នៅ ឯ ក្នុង ស្រុក ដែល ពួក គេ ដឹង ច្បាស់ ថា គេ កំពុង ធ្វើ អ្វី គឺ ការ រៀបចំ ចូល បោះឆ្នោត ថ្នាក់ជាតិ នៅ ឆ្នាំ ២០១៣ ទោះ បី មាន ឬ អត់ លោក សម រង្ស៊ី ក៏ ដោយ, យើង មិន បាច់ លើក យក បញ្ហា កែ ទម្រង់ គណៈកម្មការ ត្រួតពិនិត្យ មក និយាយ នោះ ទេ ព្រោះ ចំពោះ គូកន លោក សម រង្ស៊ី គិត ថា បញ្ហា នេះ វា លែង ជា បញ្ហា សំរាប់ ពួក គេ ទៅ ហើយ។ អ្វី ដែល ពួក គេ កំពុង ធ្វើ នៅ បរទេស ជា មួយ លោក សម រង្ស៊ី គឺ ជា ការជួយ លើក ទឹកចិត្ត លោក សម រង្ស៊ី, ទុក គាត់ ជា មេ គណបក្ស សង្គ្រោះជាតិ ដែល ក្លាយ ទៅ ជា គណបក្ស និរទេស រួច ទៅ ហើយ និង សំរាប់ ស្វែង រក ថវិកា សំរាប់ គណបក្ស សមរង្ស៊ី ឥត សម រង្ស៊ី និង គណបក្ស សិទ្ធិ មនុស្ស តែ ប៉ុណ្ណោះ។ យើង ជឿ ជាក់ ថា ថ្ងៃ ដែល លោក សម រង្ស៊ី គាត់ ភ្ញាក់ ពី ដំណេក គឺ ជា ថ្ងៃ ប្រកប ដោយ សេចក្តី ឈឺ ចិត្ត ជា ទីបំផុត សំរាប់ គាត់ បើ សិន ជា លោក មាន ចិត្ត ជា អ្នក ស្នេហា ជាតិ ពិត។

ប៉ុន្តែ លោក សម រង្ស៊ី អាច ចៀសវៀង អន្ទាក់ ជា មរណៈ នេះ បាន ងាយ ស្រួល ណាស់ គឺ សេចក្តី សំរេចចិត្ត របស់គាត់ ធ្វើ ពហិការ ក្នុង ការបោះឆ្នោត គ្មាន សេរី និង គ្មាន យុត្តិធម៌ នៅ ឆ្នាំ ២០១៣ ដែល ជា ការបោះឆ្នោត ឲ យួនឈ្នះ តែ ប៉ុណ្ណោះ។

យើង ឃើញ ថា បច្ចុប្បន្ន នេះ ប្រជារាស្ត្រខ្មែរ គាត់ ឥត ឃើញ មាន រូបភាព នយោបាយ ខ្មែរ ណា មួយ ដែល បង្ហាញ ការ

សង្ឃឹម ដល់ គាត់, ផ្ទុយ ទៅ វិញ សកម្មភាព នយោបាយ នៅ ក្នុង ស្រុក ឥឡូវ នេះ រឹតតែ ធ្វើ ឲ គាត់ ខ្លាច កាន់តែ ខ្លាំង ឡើង ព្រោះ គាត់ គិត ថា បើ នាំ គ្នា ចូល លោក សម រង្ស៊ី, ចុះ បើ លោក សម រង្ស៊ី ដូរ ទៅ ចូល លោក ហ៊ុន សែន ដូច ទ្រង់ រ៉ាណារិទ្ធ ពី មុន, តើ នរណា ជា អ្នក ទទួល ផល អាក្រក់ គឺ គ្មាន នរណា ក្រៅ ពី គាត់ នោះ ឯង។ ហេតុ នេះ ឯង បាន ជា មាន ពាក្រ ខ្មែរ មួយ និយាយ ជា ចំអក ថា : « នយោបាយ នយោ បោក »។ តែ បើ ប្រជារាស្ត្រខ្មែរ គាត់ នៅ តែ ខ្លាច នយោបាយ គឺ ច្បាស់ ជា អ្នក នយោបាយ នៅ តែ បោក គាត់ ជា និច្ច ដ៏ ដែល៕